ពលរដ្ឋខ្លាំង ជាតិខ្លាំង
STRONG PEOPLE STRONG NATION

# វេទិកាពលរដ្ឋ

## FORUM FOR THE PEOPLE

សហរដ្ឋអាមេរិក ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣

# សេចក្តីថ្លែងការណ៍

## ស្នើរដ្ឋាភិបាលធ្វើវេទិកាសាធារណៈ
## អំពីលទ្ធផលទស្សនកិច្ចរបស់លោក ហ៊ុន សែន នៅប្រទេសចិន

**វេទិកាពលរដ្ឋ** កត់សម្គាល់ឃើញថា បន្ទាប់ពីវិលត្រឡប់ពីការបំពេញទស្សនកិច្ច របស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាល បាននាំគ្នាអះអាងព្រោងព្រាត អំពីជោគជ័យដ៏ធំធេង នៃកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ពីទស្សនកិច្ចនេះ។ លោក **ហ៊ុន សែន** និង ភាគីចិន បានចុះកិច្ចព្រមព្រៀង សន្យាកសាងជោគវាសនាចិន-កម្ពុជាតែមួយនៅថ្ងៃអនាគត ការពារគ្នាលើនយោបាយការទូតអន្តរជាតិ ជួយគ្នាលើវិស័យយោធា … ភាគីលោក **ហ៊ុន សែន** បានទទួលជំនួយឥតសំណង យ៉ាងតិច៤៥លានដុល្លារ ពីរដ្ឋាភិបាលចិន លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជាដើម។

**វេទិកាពលរដ្ឋ** ស្នើរដ្ឋាភិបាលធ្វើវេទិកាសាធារណៈ ដើម្បីបើកឱកាសសម្រាប់ប្រជាពលរដ្ឋ សួរដេញដោលឲ្យអស់សង្ស័យ ទាក់ទងនឹងជំនួយនិងកម្ចីនានា ដែលធ្វើឡើងក្នុងអំឡុងដំណើរទស្សនកិច្ចលើកនេះ។ យើងខ្ញុំលើកសំណើនេះ ដោយសារតែទទួលបានមតិជាច្រើនពីប្រជាពលរដ្ឋទាំងក្នុងនិងក្រៅប្រទេស ដែលសម្តែងការបារម្ភថា កម្ចីឬអំណោយទាំងនោះ អាចមានការបិទបាំងថា លុយខ្ចីពីចិន ឬ អំណោយរបស់ចិន ប៉ុន្តែ រដ្ឋាភិបាលប្រគល់សម្បត្តិរដ្ឋឲ្យភាគីចិនជាការទូទាត់រួចហើយ ក្នុងរូបភាពបន្លំជាវិនិយោគ ដូចជា ព្រលានយន្តហោះ កំពង់ផែ និង មជ្ឈមណ្ឌលពាណិជ្ជកម្មសំខាន់ៗ នៅរាជធានីភ្នំពេញ ខេត្តកែប ព្រះសីហនុ ខេត្តកោះកុង … ។

**វេទិកាពលរដ្ឋ** មើលឃើញថា ការបារម្ភបែបនេះ របស់ប្រជាពលរដ្ឋខ្មែរម្ចាស់ប្រទេស មានភាពសមហេតុសមផលច្រើន ព្រោះ ផ្អែកលើស្ថានភាពជុនដាប នៃសេដ្ឋកិច្ចកម្ពុជាសព្វថ្ងៃ ភាគីចិនពុំមានសង្ឃឹមថា រដ្ឋាភិបាលលោក **ហ៊ុន សែន** មានលទ្ធភាពឯណាទៅសងចិនតាមកំណត់នោះទេ គឺមានតែខ្ចីថែម។ ម្យ៉ាងទៀត ក្នុងសភាពការណ៍ប្រកួតប្រជែងដ៏តានតឹងបច្ចុប្បន្ន រវាងចិននិងអាមេរិក ភាគីចិនត្រូវការត្រៀមខ្លួនហ្មត់ចត់ណាស់ ជាពិសេស ការត្បិតត្បៀតលើប្រព័ន្ធចំណាយហិរញ្ញវត្ថុ ទាំងព្យាយាមកាត់បន្ថយជាអតិបរមា នូវកញ្ចប់ជំនួយនិងកម្ចីរបស់ខ្លួន ដល់បណ្តាសម្ព័ន្ធមិត្តផង។ ភ័ស្តុតាងជាក់ស្តែង ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ភាគីចិនផ្តល់ជំនួយ និងកម្ចីតិចតួចបំផុត ដល់រដ្ឋាភិបាលលោក **ហ៊ុន សែន** ទោះបីជាលោក **ហ៊ុន សែន** ខិតខំអែបអបអង្វរចិនយ៉ាងណាក៏ដោយ។ ដូច្នេះ គ្មានមូលហេតុសមទំនងទេ ដែលចិនផ្តល់អំណោយនិងកម្ចីច្រើននៅពេលនេះ គឺមានតែកាត់យកទ្រព្យរបស់កម្ពុជា ក្នុងរូបភាពវិនិយោគ។

**វេទិកាពលរដ្ឋ** សង្ឃឹមថា រដ្ឋាភិបាលនៃលោក **ហ៊ុន សែន** មានសេចក្តីក្លាហានគ្រប់គ្រាន់ ឆ្លើយតបនឹងការព្រួយបារម្ភ ពីប្រជាពលរដ្ឋខ្មែរម្ចាស់ប្រទេស ដោយរៀបចំធ្វើវេទិកាសាធារណៈ ឲ្យពលរដ្ឋបានសួរដេញដោល ជម្រះកង្វល់របស់ពួកគាត់។

**ប្រធាន វេទិកាពលរដ្ឋ**

**គឹម សុខ**

Address: 58 Poplar Street, Plains PA 18 705, USA